ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ដោយៈឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃ គ ជ អ ប

- សូមគោរពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ ជ អ ប
- ឯកឧត្តម លោកជំទាវ លោក លោកស្រីជាសមាជិកអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃគ ជ អ ប
- ឯកឧត្តមប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងឯកឧត្តមប្រធានសម្ព័ន្ធភាពក្រុមប្រឹក្សាឃុំ សង្កាត់
- ឯកឧត្តម លោកជំទាវអគ្គនាយក អគ្គនាយិកា អគ្គាធិការ ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័នពាក់ព័ន្ធ
- លោក លោកស្រីប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍
- សូមគោរព លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ដែលមានវត្តមាននៅទីនេះ

ថ្ងៃនេះក្រសួងមុខងារសាធារណៈ អង្គសិក្ខាសាលាទាំងមូល មានសេចក្តីសោមនស្សរីករាយជាអនេកប្បការ ដោយមានកិត្តិយសស្វាគមន៍ សម្តេចក្រឡាហោម ឯកឧត្តម លោកជំទាវ និងសូមគោរព ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្តេចក្រឡាហោម

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលបានអញ្ជើញចូលរួម ក្នុងអង្គសិក្ខាសាលាផ្សព្វផ្សាយ **ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសំរាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** នេះផងដែរ។ ក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍អំពីលទ្ធផលនៃអង្គសិក្ខាសាលាជូនអង្គពិធីទាំងមូលបានជ្រាបដូចខាងក្រោម៖

## ១. សមាសភាពចូលរួម

អង្គសិក្ខាសាលាពេញមួយថ្ងៃនេះបានប្រព្រឹត្តទៅប្រកបដោយភាពរលូន ដែលក្នុងនោះមានវត្តមានអញ្ជើញចូលរួមមកពី៖

- ថ្នាក់ជាតិរួមមាន៖ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ អគ្គនាយករង អគ្គាធិការរង ប្រធានាយកដ្ឋាន អនុប្រធាននាយកដ្ឋាន. លេខាធិការដ្ឋាន គ ជ អ ប ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ.នៃក្រសួង ស្ថាប័ន និងក្រុមការងាររៀបចំសិក្ខាសាលាផ្សព្វផ្សាយ**ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសំរាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- ថ្នាក់ក្រោមជាតិរួមមាន៖ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ អភិបាលរងរាជធានី ខេត្ត អភិបាលខ័ណ្ឌ ប្រធានសម្ពន្ធភាពក្រុមប្រឹក្សាឃុំ សង្កាត់ នាយករដ្ឋបាល ប្រធានមន្ទីមុខងារសាធារណៈ នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុខ័ណ្ឌដែលអញ្ជើញមកពីបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ សរុបទាំងអស់ចំនួន ៣៨៨នាក់ ក្នុងនោះស្ត្រីចំនួន៤៨នាក់។

## ២. ដំណើរការនៃអង្គសិក្ខាសាលា

អង្គសិក្ខាសាលានេះបានប្រព្រឹត្តទៅអស់រយៈពេលពេញមួយថ្ងៃ។បន្ទាប់ពីសុន្ទរកថាបើកដោយ ខ្ញុំបាទផ្ទាល់ បន្តដោយការធ្វើបទបង្ហាញជូនសិក្ខាសាលាជ្រាបលើប្រធានបទចំនួន២ដោយឯកឧត្តម **ថោ សេដ្ឋាណា** អនុរដ្ឋលេខាធិការនិងជាប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងមុខងារសាធារណៈ៖

ប្រធានបទទី១ពាក់ព័ន្ធនឹងគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស នៅថ្នាក់ក្រោមជាតិ។

បទបង្ហាញនេះសង្កត់ធងន់លើវិសាលភាព ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្រ្តនៅក្នុងការអនុវត្តដើម្បីសម្រេចគោលដៅនីមួយៗនៃគោលនយោបាយនេះ។

ក្នុងបទបង្ហាញនេះដែរ ឯកឧត្តមបានពន្យល់លម្អិតពីក្រសួង ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត ការបង្កើតយន្តការផ្សេងៗដើម្បីគាំទ្រដល់ការអនុវត្ត ផែនការសកម្មភាព និងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តគោលនយោបាយនេះផងដែរ។

ប្រធានបទទី២ពាក់ព័ន្ធនឹងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ បទបង្ហាញនេះសង្កត់ធ្ងន់លើមូលដ្ឋានគតិយុត្ត និងខ្លឹមសារសំខាន់ៗនៃព្រះរាជក្រឹត្យ ដោយពន្យល់មួយជំពូកម្តងៗ ព្រមទាំងបានគូសបញ្ជាក់ចំណុចសំខាន់ៗដែលទាក់ទងនឹងជំពូកនីមួយៗជូនអង្គសិក្ខាសាលាបានជ្រាប។

នៅក្នុងការធ្វើបទបង្ហាញទាំងពីរប្រធានបទនេះ អង្គសិក្ខាសាលាទាំងមូលបានមានចំណាប់អារម្មណ៍ និងជ្រួតជ្រាបគ្រប់ៗគ្នានូវខ្លឹមសារនៃប្រធានបទ ព្រមទាំងបានតាំងជាសំនួរជូនដល់វាគ្មិន នៅក្នុងអង្គសិក្ខាសាលាដើម្បីឆ្លើយតបដែលរួមមាន ១៤ សំនួរដូចខាងក្រោម៖

១/ ក្នុងមាត្រា៣៦៖ តើការឡើងថ្នាក់ និង/ឬ ឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខេត្ត ស្រុក ឃុំ និងសង្កាត់ក្នុងស្រុកត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលខេត្ត ឬដីការរបស់រដ្ឋបាលសាមី?

២/ ក្នុងមាត្រា២៨៖ នៃច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់ បានចែងថា ស្មៀនឃុំសង្កាត់ តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ តើព្រះរាជក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការតែងតាំងនិងការផ្លាសប្តូរស្មៀនឬទេ?

៣/ ក្នុងមាត្រា៤៤៖ តើមន្ត្រីបំរើការងារនៅរដ្ឋបាលឃុំ ឬរដ្ឋបាលស្រុក ត្រូវបានចេញដោយដីការបស់ខេត្ត ឬរដ្ឋបាលសាមី? (ការដាក់អោយស្ថិតនៅក្រៅក្របខណ្ឌដើម)។

៤/ ក្នុងមាត្រា៤៩៖ ករណីមន្ត្រីឬប្រធានការិយាល័យឬនាយកទីចាត់ការ សុំអនុញ្ញាតច្បាប់ឈប់សម្រាកទៅក្រៅប្រទេស តើអនុវត្តតាមខ្លឹមសារនេះ ឬអនុវត្តតាមខ្លឹមសារអនុក្រឹត្យ ២១៧ ដែលត្រូវសុំអនុញ្ញាតច្បាប់ទៅក្រសួងមហាផ្ទៃ? ក្នុងករណីប្រធានមន្ទីរ អង្គភាព សុំអនុញ្ញាតឈប់សម្រាក តើត្រូវការអនុញ្ញាតត្រឹមអភិបាលខេត្តឬរដ្ឋមន្ត្រីក្រសួងសាមី?

៥/ ក្នុងមាត្រា ៧១ តើមានវិសាលភាពអនុវត្តចំពោះបុគ្គលិកជាប់កិច្ចសន្យា (NCDD) ឬទេ? ដូចជា៖ PPMA ទីប្រឹក្សាបច្ចេកទេស....?

៦/ ការផ្ទេរឬព្យួរ តើសាមីខ្លួននៅមានវត្តមានដែរឬទេ?(ពេលកំពុងដាក់ពាក្យ)

៧/ ការសុំឈប់សំរាករបស់រាជការ តើមានការកំណត់ពេលវេលាជូនគាត់ដែរឬទេ?

៨/ ពេលណាត្រូវបានរាជរដ្ឋាភិបាលសំរេចបញ្ចូលក្របខណ្ឌជូនមន្ត្រីជាប់កិច្ចសន្យាចូលក្របខណ្ឌរដ្ឋដោយស្វ័យប្រវត្តប្រចាំឆ្នាំ តាមរាជធានី ខណ្ឌ ដោយមន្ត្រីទាំងនោះបានបំរើការងារយូរឆ្នាំមកហើយ ជាករណីចាំបាច់របស់អង្គភាព ដោយខ្ញុំបាន

ដឹងថាថ្មីៗ រដ្ឋាភិបាលបានសំរេចជូនមន្ត្រីជាប់កិច្ចសន្យាតាមក្រសួងសុខាភិបាលអោយចូលក្របខ័ណ្ឌដោយស្វ័យប្រវត្តប្រមាណជិត ៣០០០នាក់។

៩/ ស្នើបកស្រាយ "បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញនិងផ្ទេរទៅឱ្យក្រុមប្រឹក្សា" សូមលើក ឧទាហរណ៍ជាមន្ត្រីជាប្រភេទណា ?

១០/ ការផ្ទេរ និងការផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុងព្រះរាជក្រឹត្យនេះអនុញ្ញាតឱ្យផ្ទេរទៅវិញទៅមក រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយនិងថ្នាក់ក្រោមជាតិមួយទៀត។ ដោយការផ្ទេរនេះអាចធ្វើឡើងក្នុងអង្គតែមួយនៃមន្ត្រីរាជការនោះ។ ប្រសិនបើការផ្ទេរនិងការផ្លាស់ប្តូរនោះក្រៅអង្គតែមួយតើត្រូវធ្វើយ៉ាងដូចម្តេចរវាង៖

- នៅដែនរដ្ឋបាលដែនដីមួយ(ខេត្តតែមួយ)
- រដ្ឋបាលដែនដីមួយនិងរដ្ឋបាលដែនដីមួយទៀត
- ថ្នាក់ក្រោមជាតិនិងថ្នាក់ក្រោមជាតិ

១១/ ការតែងតាំងត្រូវយកអ្នកដែលមានឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់ជាង។ តែមន្ត្រីដែលមានឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់នោះ៖

- សមត្ថភាពមានកម្រិត
- មានទំនាក់ទំនងល្អ មន្ទីរ អង្គភាព
- មានទំនាក់មិនល្អផ្ទៃក្នុង
- មកធ្វើការមិនពេញម៉ោងកំណត់
- មិនមានសាមគ្គីភាពផ្ទៃក្នុង

១២/ តើត្រូវយកអ្នកដែលមានឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់ ទាបជាងដើម្បីប្រគល់ភារកិច្ចឬតែងតាំងបានដែរឬអត់ ?

១៣/ តើការដំឡើងឋានន្តរស័ក្តិស្នើឡើងសម្រាប់តែក្របខណ្ឌក្រសួងមហាផ្ទៃឬយ៉ាងណា ?

១៤/ តើមន្ត្រីរាជការនៃមន្ទីរផ្សេង តែងតាំងដោយដីការខេត្តឬដោយប្រកាសរបស់ថ្នាក់ក្រសួង ?

**សំណូមពរ៖** ប្រធានបុគ្គលិកក្រសួង ស្ថាប័ន នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស រាជធានី ខេត្ត និងប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវជូន ដំណឹង និងផ្សព្វផ្សាយ (មានលិខិតជូនដំណឹង) ឱ្យបានទូលំទូលាយដល់មន្ត្រីក្រោមឱវាទមន្ទីរ

អង្គភាពឱ្យបានយល់ជ្រាបអំពីការដំឡើងថ្នាក់និងឋានន្តរស័ក្តិតាមវេន អតីតភាពការងារ ២ឆ្នាំម្តងតើការបណ្តុះបណ្តាល ការបំពេញការងារមានស្នាដៃល្អ? **ជាពិសេស** ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវយល់ច្បាស់ពីច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារមុខងារសាធារណៈដែលនៅជាធរមានឱ្យបានច្បាស់លាស់ កុំឱ្យអនុវត្តមិនច្បាស់នាំឱ្យមានកំហុសខុសឆ្គងក្នុងវិជ្ជាជីវៈ។

ចំពោះបញ្ហាប្រឈមផ្សេងទៀតដែលត្រូវរាយការជូនសម្តេចក្រឡាហោមនិងអង្គសិក្ខាសាលាជ្រាបគឺ ទី១ ចំពោះការទាមទារជាសំណូមពរ សុំឲ្យការរៀបចំលិខិតបទដ្ឋាននានាដើម្បីអនុវត្ត គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិនិងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិសូមធ្វើឲ្យបានទាន់ពេលវេលា និងឲ្យមានការផ្សព្វផ្សាយ រឺការចុះបង្រៀននៅតាមខេត្តឲ្យបានទាន់ពេលវេលាដើម្បីងាយស្រួលសហការអនុវត្តបានត្រឹមត្រូវនិងមានប្រសិទ្ធភាព។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីសិក្ខាសាលានេះ ឯកឧត្តម លោកជំទាវ លោកលោកស្រី ដែលបានចូលរួមក្នុងសិក្ខាសាលាថ្ងៃនេះ នឹងធ្វើការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលបន្តដល់មន្ត្រីរាជការនៅក្នុងអង្គភាពរបស់ខ្លួនដើម្បីឱ្យការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពអនុលោមព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងលោក តាមជួយបីបាច់ថែរក្សា **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ និងអង្គសិក្ខាសាលាទាំងមូល សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

ជាកិច្ចបន្តខ្ញុំមានកិត្តិយស សូមគោរពអញ្ជើញ **សម្តេចក្រឡាហោម** មានមតិផ្តាំផ្ញើនិងថ្លែងបិទអង្គ សិក្ខាសាលាទាំងមូលដោយក្តីគោរព។

**សូមគោរពអញ្ជើញ!សូមអរគុណ!**